រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦

# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# ការព្រួយបារម្ភលើការសម្រេចចិត្តរបស់ គ.ជ.ប ក្នុងការជ្រើសរើសអគ្គលេខាធិការ និង អគ្គលេខាធិការរងនៃ គ.ជ.ប

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) សូមកោតសរសើរចំពោះការបើកចំហព័ត៌មានអំពីបញ្ជីរាយនាមបេក្ខជនសម្រាប់មុខតំណែងជាអគ្គលេខាធិការ និងអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ ទោះបីយ៉ាងនេះក្តីយើងនៅមានការព្រួយបារម្ភជាខ្លាំងចំពោះដំណើរការជ្រើសរើសបេក្ខជនសម្រាប់មុខតំណែងទាំងនេះ ដែលមិនមានតម្លាភាពចំពោះសាធារណៈជន។

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត សូមលើកទឹកចិត្តឲ្យ គ.ជ.ប ជ្រើសយកបេក្ខភាពថ្មីមកធ្វើជាអគ្គលេខាធិការ បើពុំនោះទេវានឹងធ្វើឲ្យសាធារណៈជនបាត់ជំនឿលើ គ.ជ.ប ថ្មី ព្រោះថា អគ្គលេខាធិការជាអ្នកដឹកនាំអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ដែលជាជំនួយការដល់ គ.ជ.ប ហើយការចាត់ចែងការបោះឆ្នោតកន្លងមកបានបន្សល់ទុកនូវបញ្ហា ដែលធ្វើឲ្យភាគីពាក់ព័ន្ធ ជាពិសេសគណបក្សនយោបាយចូលរួមប្រកួតប្រជែងការបោះឆ្នោតបាត់ជំនឿលើការរៀបចំ។

គ.ជ.ប ថ្មី មានថ្នាក់ដឹកនាំថ្មី ដែលចាំបាច់ត្រូវមានអគ្គលេខាធិការថ្មី ដូច្នេះការសម្រេចជ្រើសរើសយកមនុស្សថ្មីធ្វើជាអគ្គលេខាធិការពិតជាមានសារៈសំខាន់ណាស់ក្នុងការធ្វើការជាមួយ គ.ជ.ប ថ្មី។

ជាថ្មីម្តងទៀត សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតសូមទទូចឲ្យ គ.ជ.ប ត្រូវតែបង្ហាញនីតិវិធីនៃការសម្រេចចិត្តមួយមានតម្លាភាព ដែលធ្វើឲ្យមានការជឿជាក់ទៅលើដំណើរការរៀបចំការបោះឆ្នោត ដែលនឹងប្រព្រឹត្តទៅក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ខាងមុខនេះ។


**សម្រាប់ព័ត៌មានបន្ថែម៖**

| ឈ្មោះ | អង្គការ | លេខទូរស័ព្ទ |
|---|---|---|
| • លោកស្រី ធីតា ឃឹះ | SILAKA | ០១២ ៨៣៨ ៤៦៤ |
| • លោក ណៃ វ៉ង់ដា | ADHOC | ០១២ ៥៣០ ២៥១ |
| • លោក សំ គុន្ធាមី | NICFEC | ០១២ ៨២២ ២៧៣ |
| • លោក យង់ គិមអេង | PDP-Center | ០១៦៨២៨ ២១១ |
| • លោក គល់ បញ្ញា | COMFREL | ០១២ ៩៤២ ០១៧ |
| • លោក សន ជ័យ | ANSA Cambodia | ០១២ ៤៥៥ ៦៤២ |
| • លោក ព្រាប កុល | TIC | ០១២ ៨៧៧ ៨៣៣ |

| | | |
|---|---|---|
| • លោកស្រី រស់ សុភាព | GADC | ០១២ ៦២៧ ៨៥៧ |
| • លោក ហួន ជុនឌី | CLEC | ០៩៣ ៣៤៥ ៦០២ |
| • លោក សួន ប៊ុនស័ក្តិ | CHRAC | ០៩២ ៣៤ ៤៣ ៥៧ |
| • លោកស្រី សិទ្ធ ហុងអៀង | KYA | ០១៧ ៧៨៨ ៩៥៥ |
| • លោក ជាង សុខា | YRDP | ០១២ ៣៦០ ៤៦៤ |